ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៩ .១០ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៩.២.៩៦	ព្រះរាជក្រឹត្យ ជស/រកត/០២៩៦/០៨ ស្ដីពីការរៀបចំធ្វើការជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា	៤៨៧
០២.៣.៩៦	ព្រះរាជក្រឹត្យ /ជសរកត/០៣៩៦/០៩ តែងតាំងឯកឧត្តម សៀង ឡាប្រេស្ស ជាអនុរដ្ឋលេខាធិការក្រសួងពត៌មាន	៤៩២

II ទីស្ដីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

០១.៣.៩៦	អនុក្រឹត្យលេខ ៣១ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៤៩៣
០១.៣.៩៦	អនុក្រឹត្យលេខ ៣២ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៤៩៥
០៤.៣.៩៦	អនុក្រឹត្យលេខ ៣៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	៤៩៨
០៦.៣.៩៦	អនុក្រឹត្យលេខ ៣៤ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៤៩៩
០៧.៣.៩៦	អនុក្រឹត្យលេខ ៣៥ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ	៥០០
០៧.៣.៩៦	អនុក្រឹត្យលេខ ៣៦ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៥០១
០៧.៣.៩៦	អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	៥០២
១១.៣.៩៦	អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្ដីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការ	៥០៣
១៤.៣.៩៦	អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៥០៤
១៤.៣.៩៦	អនុក្រឹត្យលេខ ៤០ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៥០៦
១៤.៣.៩៦	អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ	៥០៧

២—សេចក្តីសំរេច

០៨. ៣. ៩៦ សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា ៥០៨

១១. ៣. ៩៦ សេចក្តីសំរេចលេខ ០៤ សសរ ស្តីពីការបង្កើតក្រុមការងារសំរាប់សំរួលការដោះស្រាយឧបត្ថម្ភដល់បងប្អូនភ្នាក់ងារលើកនៅក្នុងតំបនឱ្យរាល ៥១០

១១. ៣. ៩៦ សេចក្តីសំរេចលេខ ០៥ សសរ ស្តីពីការផ្ទេរសិទ្ធិ ៥១១

III ក្រសួងរបស់ក្រសួង

១—ទីស្តីការរដ្ឋមន្ត្រីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០៥. ៣. ៩៦ ប្រកាសលេខ ០៥៤ ប្រក. សហវ ស្តីពីការបង្កើតក្រុមការងារអធិការេយសំរាប់ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យនៃអង្គការគ្រប់គ្រងគំរោង "PMU"

១៥. ៣. ៩៦ ប្រកាសលេខ ០៥៨ ប្រក. សហវ. ធរ ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន Indochine Inrurance Union ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ៥១២

២—ទីស្តីការរដ្ឋមន្ត្រីឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

០៧. ៣. ៩៦ ប្រកាសលេខ ១៤១ ភរ. ប្រក អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte Ltd ធ្វើប្រតិបត្តិការស្វែងរករកធនធានរ៉ែនៅតំបន់ភ្នំដែក ខេត្តព្រះវិហារ ៥១៣

ត

០៧. ៣. ៩៦ ប្រកាសលេខ ១៤២ ភ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte . Ltd ធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែនៅ តំបន់ក្រវ៉ា ខេត្តកំពង់ធំ ៥១៩

៣—ទីស្តីការរដ្ឋមន្ត្រី ក្រសួងពតិមាន

ប្រកាស

០៧. ៣. ៩៦ ប្រកាសលេខ ០៧២/៩៦ ពម.ប្រក អនុញ្ញាតអោយទស្សនាវដ្តី ឈ្មោះ រណសិរ្ស ២ ធ្នូ បោះពុម្ពចែកផ្សាយឡើងវិញ ៥២០

១២. ៣. ៩៦ ប្រកាសលេខ ០៧៥/៩៦ ពម.ប្រក អនុញ្ញាតជូនលោក ហ៊ួន សោភណ្ឌរិទ្ធ បើកអាជីវកម្មទូរទស្សន៍ខ្សែកាប ៥២២

៤—ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

០៤. ៣. ៩៦ ប្រកាសលេខ ១៩០ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ អំពិលព្រង ៥២៣

០៦. ៣. ៩៦ ប្រកាសលេខ ១៩៧ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ មកជាសាលាពេញលក្ខណៈ ៥២៤

៥—ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

០៥. ៣. ៩៦ ប្រកាសលេខ ១២០ ស.នបក ស្តីពីការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការិយាល័យសុខាភិបាលស្រុក ៥២៦

៦—ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

៧. ៣. ៩៦	ប្រកាសលេខ ២៦៩ ករច ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីថ្នាក់ការិយាល័យនៃមន្ទីរទេសចរណ៍ក្រុងកែប	៥៣៦

៧—ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ប្រកាស

១៥. ៣. ៩៦	ប្រកាសលេខ ១៤៦សកអ ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន ឃីពហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្តមែន KEEP GOING (H.K) INVESTMEMT LTD បញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស	៥៣៧

៨—ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០៤. ៣. ៩៦	ប្រកាសលេខ ០៣០ បទ.ប្រក ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រី បុគ្គលិករាជការ	៥៣៨
១៥. ៣. ៩៦	ប្រកាសលេខ ០៣៨ បទ.ប្រក អនុញ្ញាតអោយលោកជំទាវ ល៉ៀម សេដ្ឋា ផ្តាកការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០៣ គ្រឿង	៥៤៣

៩—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

០៤. ៣. ៩៦	សេចក្តីសំរេចលេខ ១៦៦ សសរ. មស. ក្រខ ស្តីពីការបែងចែក សិស្ស និស្សិតចំនួន ១០ នាក់ ដែលទើបបញ្ចប់ការសិក្សាក្រៅប្រទេស	៥៤៤

១០—និស្ថិការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

០៥. ៣. ៩៦	សេចក្តីសំរេចលេខ ៥៧/៩៦ កធស ស្តីពីការអនុញ្ញាតច្បាប់អោយមានស្នាក់ការថ្វាយបង្គំព្រះប្រកាសដំណឹងល្អ ពីព្រះយេស៊ូគ្រិស្ត ខេត្តកណ្តាល	៥៤៧
១៥. ៣. ៩៦	ប្រកាសលេខ ៦៨/៩៦ កធស. ប្រក ស្តីពីការបង្កើតមន្ទីរធម្មការ និង សាសនា ក្រុងកែប	៥៤៨

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០២៩៦/០៨
ស្តីពីការរៀបចំធ្វើការជំរឿនទូទៅនូវ
ប្រជារាស្ត្ររបស់ប្រទេសកម្ពុជា

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

– តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងផែនការ

ត្រាស់បង្គាប់

ជំពូក ទី ១

ការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ និង ការតែងតាំងបុគ្គលិក

មាត្រា ១ : ជំរឿនទូទៅនូវប្រជារាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាកិច្ចការរបស់ជាតិស្របតាមទម្រង់ការអន្តរជាតិ ត្រូវចាត់ចែងធ្វើក្នុង១០ឆ្នាំម្តង ។

ក្រសួងផែនការ ជាស្ថាប័នទទួលបន្ទុកធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ដោយមានវិទ្យាស្ថានជាតិស្ថិតិជាអង្គភាពប្រតិបត្តិផ្ទាល់ ។

ការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រនឹងរាប់បញ្ចូលនូវ :

១–កិច្ចប្រតិបត្តិការដំបូងរបស់ការធ្វើជំរឿន :

ក–ការរៀបចំផែនទី

ខ–ការរាប់ និងចុះបញ្ជីលំនៅឋាន

គ–ការធ្វើអង្កេត និងធ្វើជំរឿនសាកល្បង

២–ការធ្វើសំភាសន៍សំរាប់ការធ្វើជំរឿន ។

៣–កិច្ចប្រតិបត្តិការចុងក្រោយរបស់ការធ្វើជំរឿន :

ក–ការធ្វើអង្កេតសំរាប់វាយតំលៃលើការធ្វើជំរឿនដែលបានធ្វើហើយ

ខ–ការអង្កេតផ្សេងទៀតក្នុងករណីចាំបាច់

មាត្រា ២ : នាយកវិទ្យាស្ថានជាតិស្ថិតិជានាយកនៃការជំរឿនទូទៅនូវប្រជារាស្ត្រ នឹងត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ទីរផែនការ ខេត្ត–ក្រុងជួយរាល់ការងារក្នុងការធ្វើជំរឿន ។

មាត្រា ៣ : មន្ត្រីបំពេញការងារជំរឿនរួមមានអ្នកសំភាសន៍ស្រង់យកពត៌មាន អ្នកត្រួតពិនិត្យការសំភាសន៍និង ភ្នាក់ងារជំនួយការដល់កិច្ចប្រតិបត្តិការធ្វើជំរឿន ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់នាយកនៃការជំរឿនទូទៅនូវប្រជារាស្ត្រ ។ ការចាត់ចែងនេះអនុវត្តបានតែ ក្នុងអំឡុងពេលធ្វើជំរឿនតែប៉ុណ្ណោះ ។

មាត្រា ៤ : រដ្ឋមន្ត្រីក្រសួងផែនការ មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងជនសាមញ្ញដើម្បីសហការជួយធ្វើការជំរឿនទូទៅនូវប្រជារាស្ត្រ ។

ជំពូក ទី ២

ការរៀបចំធ្វើកិច្ចការជំរឿន

មាត្រា ៥ : កាលបរិច្ឆេទដ៏ជាក់លាក់នៃការផ្តើមធ្វើ និងការបញ្ចប់កិច្ចការជំរឿនព្រមទាំងសេចក្តីរាយល្អិត ពីកិច្ចការនេះនឹងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងផែនការ ។

មាត្រា ៦ : ត្រូវធ្វើជំរឿនជនគ្រប់រូប ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា វៀរលែងតែសមាជិកអង្គទូតបរទេស និងក្រុមជនដូចគ្នានឹងអង្គទូតដែរ តាមកិច្ចព្រមព្រៀងដែលត្រូវកំណត់ ឡើង ជាមួយនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៧ : ម្ចាស់លំនៅឋានគ្រប់ប្រភេទ និងអ្នកគ្រប់គ្រងទីកន្លែងនានា ត្រូវអនុញ្ញាតអោយមន្ត្រីបំពេញការងារជំរឿនបានចូលលំនៅឋាន ឬទីកន្លែងរបស់ខ្លួនក្នុងគោលដៅនៃការធ្វើជំរឿន និងអនុញ្ញាត អោយមន្ត្រីទាំងនោះបាន លាបថ្នាំពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសំគាល់ នៅតាមកន្លែងចាំបាច់នានា សំរាប់បំរើដល់ការងារធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

មាត្រា ៨ : មន្ត្រីបំពេញការងារជំរឿនទាំងឡាយ អាចសួរមេគ្រួសារ ឬសមាជិកគ្រួសារទាំងអស់ក្នុងពេលធ្វើ ជំរឿន តែតាមសំនួរដូចបានគ្រោងទុកស្រាប់ ហើយនៅតែក្នុងរង្វង់មណ្ឌលដែលបានអនុញ្ញាតអោយប្រតិបត្តិតែប៉ុណ្ណោះ ។

មាត្រា ៩ : ប្រជារាស្ត្រគ្រប់រូបត្រូវតែឆ្លើយ ដោយត្រឹមត្រូវទៅតាមការយល់ដឹងដ៏ប្រាកដរបស់ខ្លួនទៅនឹងសំនួរសំភាសន៍ ដែលមន្ត្រីធ្វើជំរឿនបានសួរដូចក្នុងមាត្រា ៨ សំរាប់ ការធ្វើជំរឿន ។

មាត្រា ១០ : រដ្ឋមន្ត្រីក្រសួងផែនការ អាចប្រកាសតែងតាំងអ្នកគ្រប់គ្រង តាមទីកន្លែងដែលមានលក្ខណៈពិសេស ធ្វើសំភាសន៍អ្នកនៅក្នុងរង្វង់គ្រប់គ្រងរបស់ខ្លួន ។

អ្នកគ្រប់គ្រងតាមទីកន្លែង ពិសេសទាំងនោះមាន :

ក–មេបញ្ជាការយោធា នគរបាល ដែលគ្រប់គ្រងនៅតាមអង្គភាពប្រមូលផ្តុំ ។

ខ–នាយនាវា ដែលគ្រប់គ្រងនៅតាមនាវារបស់ខ្លួន ។

គ-នាយកមន្ទីរពេទ្យវិកលចរិត នាយកមន្ទីរពេទ្យព្យាបាលជម្ងឺទូទៅនាយកពន្ធនាគារ នាយកមជ្ឈមណ្ឌលកែប្រែ នាយកមជ្ឈមណ្ឌលសង្គ្រោះ នាយកមន្ទីរឃុំឃាំងបណ្ដោះអាសន្ន ចៅអធិការវត្ត នាយកគ្រឹះស្ថានអប់រំដែលមានមនុស្សរស់នៅ តាមរបៀបប្រមូលផ្ដុំ ។

ឃ-អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌលសំរាកកាយ ។

ង-អ្នកចាត់ការខ្សែរថភ្លើង អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុងគ្រឹះស្ថានឧស្សាហកម្ម ។

មាត្រា ១១ : មន្ត្រីដែលគ្មានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅ បញ្ជី ឬ សំណៅកត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ។

មាត្រា ១២ : ពត៌មានជាលក្ខណៈផ្ទាល់ខ្លួន ដែលស្រង់បានក្នុងពេលប្រតិបត្តិការជំរឿនត្រូវបានយកទៅ ប្រើប្រាស់សម្រាប់តែការងារស្ថិតិប៉ុណ្ណោះ ។ ពត៌មានទាំងនោះ ទោះក្នុងករណីណាក៏ដោយនិង មានហេតុផលយ៉ាងណាក៏ដោយ ក៏ពុំត្រូវជូនទៅក្រុមសារពើពន្ធ សាលាជំរះក្តី ឬ អង្គការដទៃណាទៀតបានឡើយ ។ ពាក្យបណ្តឹងទៅសាលាជំរះក្តី ការទារពន្ធអាករដែលសំអាង លើពត៌មានផ្ទាល់ខ្លួនទាំងឡាយដែលស្រង់បានពីប្រតិបត្តិការជំរឿនត្រូវទុកជាមោឃៈ ។

ជំពូក ទី ៣

ទណ្ឌកម្ម

មាត្រា ១៣ : ត្រូវទទួលទណ្ឌកម្មថ្នាក់ទី ២ ដូចមានក្នុងមាត្រា ៤០ ជំពូកទី៥ ក្នុងសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ចំពោះ :

ក-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលរាជការបានចាត់អោយជួយធ្វើកិច្ចការជំរឿន ហើយមិនព្រមបំពេញមុខការរបស់ខ្លួន ឬ មិនព្រមបំពេញមុខការរបស់ខ្លួនអោយបានចប់សព្វគ្រប់ ឬ ធ្វើការនោះដោយធ្វេសប្រហែលមិនសមហេតុសមផល ឬ មិនប្រតិបត្តិការបទបញ្ញត្តិណាមួយ ដែលបានបង្កើតមកសំរាប់អនុវត្តន៍ព្រះរាជក្រឹត្យនេះ ។

ខ-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលតំរោងសួរដោយចេតនា ឬ បំភ្លៃសំនួរខុសពីសំនួរគ្រោងទុក ឬ បញ្ជូនពត៌មានមិនពិតដោយចេតនាមកទីចាត់ការជំរឿន ។

គ-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលលួចប្តូរឯកសារ (ក្រដាសថាសកុំព្យូទ័រ ខ្សែអាត់) ឬពត៌មានសំងាត់ ធ្វើអោយខូចខាត ឬ បាត់បង់ឯកសារជំរឿន ។

ឃ-មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលលួចបញ្ចេញពត៌មានដែលខ្លួនបានទទួលពីការធ្វើជំរឿន ។

មាត្រា ១៤ : ត្រូវទទួលពិន័យជាប្រាក់ពី ៥.០០០ រៀល (ប្រាំពាន់រៀល) ដល់ ៥០០.០០០ រៀល (ប្រាំរយ ពាន់រៀល) និងតម្រូវអោយអនុវត្តតាមមាត្រា ៧ និង មាត្រា ៩ នៃព្រះរាជក្រឹត្យនេះ ចំពោះ :

ក-ជនណាអោយចម្លើយខុសដោយចេតនា ឬមិនព្រមឆ្លើយនូវសំនួរ ដែលមន្ត្រីបំពេញការងារជំរឿនបានសួរ ។

ខ-ម្ចាស់ ឬអ្នកគ្រប់គ្រងលំនៅឋាន និងមូលដ្ឋានទាំងឡាយណាដែល មិនព្រមអនុញ្ញាតអោយមន្ត្រីបំពេញការងារជំរឿន ចូលលំនៅឋាន ឬមូលដ្ឋានខ្លួនគ្រប់គ្រង ដើម្បីស្រង់យកពត៌មានសំរាប់ការធ្វើជំរឿន ។

គ-ជនទាំងឡាយណាដែលបានមកធ្វើអោយបាត់ ឬ ធ្វើអោយខូចដោយចេតនានូវអក្សរសញ្ញា ឬលេខដែលមន្ត្រីបំពេញការងារជំរឿនបានចាត់ចែងគូរ បិទ ឬ ព្យួរទុកសំរាប់ការងារជំរឿន ។

ឃ-ជនទាំងឡាយណាដែលចូលដោយគ្មានការអនុញ្ញាតទៅក្នុងទីកន្លែងរក្សាទុកឯកសារជំរឿន ។

ង-ជនទាំងឡាយណា ដែលបង្កការលំបាក ឬរាំងមិនអោយមន្ត្រីបំពេញការងារជំរឿនបាន បំពេញភារកិច្ចរបស់គេដោយសុវត្ថិភាព ។

ជំពូក ទី ៤

ចរិកាក្នុងការធ្វើជំរឿន

មាត្រា ១៥ : ចរិកាក្នុងការរៀបចំធ្វើជំរឿនទូទៅនូវប្រជារាស្ត្រត្រូវស្ថិតក្នុងតំរោងចរិកាជាតិ ។

រដ្ឋមន្ត្រីក្រសួងផែនការត្រូវគ្រោងទុក និងចាត់ចែងប្រើប្រាស់ថវិកាជាតិ ឬ ថវិកាជំនួយអន្តរជាតិសំរាប់កិច្ចការនេះ ។

ជំពូក ទី ៥

អវសានបញ្ញត្តិ

មាត្រា ១៦ : នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី ២ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ១៧ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ ,

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រី ២

ព្រះហស្តលេខា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

ជា ចាន់តូ

* * *

ព្រះរាជក្រឹត្យជស./រកត/០៣៩៦/០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **សៀង ឡាប្រេស្ស** ជាអនុរដ្ឋលេខាធិការក្រសួងពត៌មាន ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិជូនចំពោះឯកឧត្តម **អ៊ុង ផន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច និងជាសមាជិកសភាមណ្ឌលស្វាយរៀង ដែលបានបរិច្ចាគថវិកាផ្ទាល់ចំនួន ១០៤.៨៣៩.០០០ រៀល សំរាប់កសាងអាគារសិក្សា និងមណ្ឌលសុខភាពនៅក្នុងខេត្តស្វាយរៀង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តន៍អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត កំពង់ចាម ។

សំរេច

មាត្រា១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះ សប្បុរសជនចំនួន ៤៩ រូប ដែលបានបរិច្ចាគថវិកាចូលរួមជួយកសាងសំណង់ផ្សេងៗ ជាប្រយោជន៍សាធារណៈ នៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយ « មាស » ស្ថាបនាជាតិ :

១-ព្រះតេជគុណ ប្រាក់ កន	បរិច្ចាគថវិកា ២០.០០០ ដុល្លារអាមេរិក
២-លោក ថន លាងអ៊ីម	បរិច្ចាគថវិកា ១៨.៧៥០ ដុល្លារអាមេរិក
៣-លោក ជា លីម៉េង	បរិច្ចាគថវិកា ២៤.៥០០ ដុល្លារអាមេរិក
៤-លោក ស៊ឹម សុវណ្ណ	បរិច្ចាគថវិកា ៣៩.១០០.០០០ រៀល
៥-លោក ឃី ឈា	បរិច្ចាគថវិកា ៤៦.០០០.០០០ រៀល
៦-ព្រះតេជគុណ អោម ញឹប	បរិច្ចាគថវិកា ៣៥.០០០.០០០ រៀល
៧-លោក អ៊ិន លាង	បរិច្ចាគថវិកា ១២.៦២០ ដុល្លារអាមេរិក

៨–លោក សៀង ហួត បរិច្ចាគថវិកា ១៦.០០០ ដុល្លារអាមេរិក

៩–លោក ហែន ស្រេង បរិច្ចាគថវិកា ១៣.០០០ ដុល្លារអាមេរិក

១០–លោក យាយ ក្រូចឈាន បរិច្ចាគថវិកា ១០.០០០ ដុល្លារអាមេរិក

ខ–មេដាយ « ប្រាក់ » ស្ថាបនាជាតិ :

១–ព្រះតេជគុណ ហាស់អ៊ី បរិច្ចាគថវិកា ១៨.០០០.០០០ រៀល

២–លោក ស្រ៊ុន អេងហ៊ាង បរិច្ចាគថវិកា ២០.០០០.០០០ រៀល

៣–លោក ម៉ែន សារុន បរិច្ចាគថវិកា ៨.០០០ ដុល្លារអាមេរិក

៤–លោក ប៉ែន វង់ បរិច្ចាគថវិកា ៦.០០០ ដុល្លារអាមេរិក

៥–លោក តែ ហួ បរិច្ចាគថវិកា ៥.០០០ ដុល្លារអាមេរិក

៦–លោក ឈីន យាយសាញ់ បរិច្ចាគថវិកា ២០.២៩៧.០០០ រៀល

៧–លោក ឯក សារិន បរិច្ចាគថវិកា ៨.៩០០ ដុល្លារអាមេរិក

៨–លោក អ៊ុំ សុខ បរិច្ចាគថវិកា ៥.០០០ ដុល្លារអាមេរិក

ខ–មេដាយ « សំរិទ្ធ » ស្ថាបនាជាតិ :

១–ព្រះតេជគុណ អ៊ុន អាន បរិច្ចាគថវិកា ១១.០០០.០០០ រៀល

២–ព្រះគ្រូ យ៉ង់ សុខ បរិច្ចាគថវិកា ១.០០០ ដុល្លារអាមេរិក

៣–ព្រះតេជគុណ ឆាយ ឈាវ បរិច្ចាគថវិកា ៣.០០០.០០០ រៀល

៤–លោក មិន គីម បរិច្ចាគថវិកា ៣.០០០ ដុល្លារអាមេរិក

៥–លោក ប៉ោ សំអឿន បរិច្ចាគថវិកា ១.២១៨ ដុល្លារអាមេរិក

៦–លោក ហេង ហួនយី បរិច្ចាគថវិកា ៤.០០០ ដុល្លារអាមេរិក

៧–លោក ហេង ស៊ីម បរិច្ចាគថវិកា ៣.៩៥០ ដុល្លារអាមេរិក

៨–លោក ង៉ា ហេង បរិច្ចាគថវិកា ២.៧៥០ ដុល្លារអាមេរិក

៩–លោក ប៊ុន គន បរិច្ចាគថវិកា ៤.២០០ ដុល្លារអាមេរិក

១០–លោកយាយ ស៊ីវ គីមឆេង បរិច្ចាគថវិកា ២.៦០០ ដុល្លារអា

១១–លោក ជី គួ បរិច្ចាគថវិកា ១.៧០០ ដុល្លារអាមេ

១២–លោក ប៉េង ស៊ា បរិច្ចាគថវិកា ១.៥០០ ដុល្លារអាមេរិក

១៣–លោក ទូច ឆៃហ៊ត់ បរិច្ចាគថវិកា ២.៧២៥.៨០០ រៀល

១៤–លោក ហោ ប៊ុនលី បរិច្ចាគថវិកា ១.៥០០ ដុល្លារអាមេរិក

១៥–លោក អ៊ុន អ៊ី បរិច្ចាគថវិកា ៣.០០០.០០០ រៀល

១៦-លោក រ៉ាន់ អន	បរិច្ចាគថវិកា	៣.២០០.០០០ រៀល
១៧-លោក ឈុំ	បរិច្ចាគថវិកា	១.២៥០ ដុល្លារអាមេរិក
១៨-ឧត្តមសេនីយ៍ អ៊ុយ សារិន	បរិច្ចាគថវិកា	៥.០០០.០០០ រៀល
១៩-លោក ស៊ុយ ហ៊ាន	បរិច្ចាគថវិកា	៣.០០០.០០០ រៀល
២០-លោក អ៊ី គីហ៊ាង	បរិច្ចាគថវិកា	៣.៥៥០.០០០ រៀល
២១-លោក មុំ រ៉ាន់	បរិច្ចាគថវិកា	៤.៥០០.០០០ រៀល
២២-លោក យ៉ុន ឈុន្នី	បរិច្ចាគថវិកា	៣.៩០៥.៥០០ រៀល
២៣-លោក មាស ខ្មៅ	បរិច្ចាគថវិកា	៣.០០០.០០០ រៀល
២៤-លោក លូ គីមឈន់	បរិច្ចាគថវិកា	២.៤២០ ដុល្លារអាមេរិក
២៥-លោក វ៉េង ហួ	បរិច្ចាគថវិកា	១.៦០០ ដុល្លារអាមេរិក
២៦-លោក ម៉ុក សុន	បរិច្ចាគថវិកា	១.៦០០ ដុល្លារអាមេរិក
២៧-លោក ប៉ិច ប៊ុនខឿន	បរិច្ចាគថវិកា	១.០៩០ ដុល្លារអាមេរិក
២៨-លោកយាយ ជូ ឡាង	បរិច្ចាគថវិកា	១.៨០០ ដុល្លារអាមេរិក
២៩-លោក ជួប ឡាង	បរិច្ចាគថវិកា	១.២០០ ដុល្លារអាមេរិក
៣០-លោក សួ ប៊ិយ	បរិច្ចាគថវិកា	១.២០០ ដុល្លារអាមេរិក
៣១-លោក ហាន់ ស្រ៊ាន	បរិច្ចាគថវិកា	៩.០០០.០០០ រៀល

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត កំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

សំរេច

មាត្រា១ : តែងតាំងលោក **ហៀក ម៉េងហួ** ជាទីប្រឹក្សារបស់ឯកឧត្តម **អ៊ុង ហួត** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណប្ញទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិជូនចំពោះអង្គការ YWAM ដែលបានធ្វើអំណោយជាសំលៀកបំពាក់ចំនួន ៥០.០០០កំប្លេរ ជូនរាជរដ្ឋាភិបាលកម្ពុជា សំរាប់ចែកអោយប្រជារាស្ត្រក្រីក្រ ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៥ អនក្រ.តត

ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤

ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ វរសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព ÷ លោក វរសេនីយ៍ទោ **ចិន សារាយ** អត្តលេខ ០០០៧៦៨ មេបញ្ជាការរងកងពលតូចទ័ពព្រៃទី១ អគ្គសេនាធិការ ដែលបានពលីក្នុងពេលបំពេញបេសកកម្មលើសមរភូមិ ផ្លូវជាតិលេខ ១០ នាថ្ងៃទី ១៧ កុម្ភៈ ឆ្នាំ ១៩៩៦ ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្ត

អនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិ ជូនចំពោះឯកឧត្តម **ញឹម វណ្ណដា** ដែលមានសទ្ធាជ្រះថ្លា បានជួយកសាងអាគារសិក្សា ១ខ្នង នៅសាលាបឋមសិក្សាគងជ័យ ស្រុក អូររាំងឪ ខេត្តកំពង់ចាម អស់ទឹកប្រាក់ ចំនួន ៥០.០០០.០០០រៀល។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត កំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរដ្ឋមន្ត្រីក្រសួងពត៌មាន

សំរេច

មាត្រា១ : ត្រូវបានតែងតាំងលោក **ស៊ូ នី** ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងពិធីការក្រសួងពត៌មាន ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណប្ញទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៨ អនក្រ.តត

ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រី រាជការ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ -៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ -៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់សហលក្ខន្តិកៈមន្ត្រី-រាជការ ស៊ីវិល ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ត្រង់ជំពូកទី ១០ មាត្រា ៦៣
- តាមសំណើរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សំរេច

មាត្រា១ : យល់ព្រមពន្យារពេលចូលនិវត្តន៍ចំនួន ០១ឆ្នាំ តទៅទៀតជូនលោក **តាន់ ហៃសៀន** ប្រធាននាយកដ្ឋានផ្លូវថ្នល់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដោយគិតចាប់ ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ដល់ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលោក **តាន់ ហៃសៀន** ត្រូវទទួលបន្ទុកអនុវត្តរៀងៗ ខ្លួនតាមខ្លឹមសារនៃ អនុក្រឹត្យនេះចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ .

សំរេច

មាត្រា១ : ត្រូវបានប្រគល់មេដាយ «សេរីវឌ្ឍន៍» ស្ពាន់ ប្រាបនាជាតិ ជូនសប្បុរសជន ០២រូប ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងអាគារសិក្សានៅសាលាបឋមសិក្សាបឹងឈូកប្រជុំវង្ស ក្នុងសង្កាត់និរោធ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញដូចមានរាយនាមខាងក្រោម ÷

១-លោក **ជា សុជាតិវង្ស** បរិច្ចាគប្រាក់ ២.៥០០ ដុល្លារអាមេរិក

២-លោក **ម៉ែន ឈាង** បរិច្ចាគប្រាក់ ១.៦០០ ដុល្លារអាមេរិក

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៤០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា១ : ត្រូវបានប្រគល់មេដាយ «ប្រាក់» ស្ថាបនាជាតិ ជូនចំពោះលោក **ជួន ឈឿន** រស់នៅទីក្រុងភ្នំពេញ ដែលបានជួយកសាងទីចាត់ការសាលាបឋមសិក្សាសូទិបមួយខ្នងនៅក្នុងឃុំ សូទិប ស្រុកជើងព្រៃ ខេត្តកំពង់ចាម អស់ទឹកប្រាក់សរុប ៩.០០០ ដុល្លារអាមេរិក ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៤១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ។

សំរេច

មាត្រា១ :ត្រូវបានប្រគល់មេដាយ «មាស » ស្ថាបនាជាតិជូនចំពោះលោក **ឡី ហេង** តំណាងក្រុមហ៊ុន **សាំងឡេង** អន្តរជាតិ ដែលបានជួយកសាងទីស្នាក់ការសង្កាត់ របងសាលាសង្កាត់ និងផ្លូវលំក្រាលគ្រួសក្រហម នៅក្នុងសង្កាត់ក្រាំងធ្នង់ អស់ទឹកប្រាក់សរុប ៤៥.០០០ ដុល្លារអាមេរិក ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

២—សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ០៣ សសរ
ស្តីពីការបង្កើតក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

ប្រការ១ : បង្កើតក្រុមការងារជាតិមួយឈ្មោះថា « ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា » ដើម្បី អភិវឌ្ឍន៍វិស័យឧត្តមសិក្សា ។

ប្រការ២ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានសមាសភាពដូចខាងក្រោម :

+ ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ ប្រធាន

+ ឯកឧត្តម **តូល ឡោះ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

+ ឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រី ក្រសួងផែនការ សមាជិក

+ ឯកឧត្តម **តាវ សេងហួរ** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សមាជិក

+ ឯកឧត្តម **ឈា ចាំង** រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សមាជិក

+ ឯកឧត្តម **ពូ សុធីរៈ** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក

+ ឯកឧត្តម **នុត ណារ៉ាង** រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

+ លោក **អ៊ុច ថុន** តំណាងគ្រឹះស្ថានឧត្តមសិក្សា សមាជិក

+ លោក **តឹក ទុំយ** តំណាងនយោជកឯកជនជាតិ ទីប្រឹក្សា

+ លោក **អេឡា ជូ** តំណាងនយោជកឯកជនបរទេស ទីប្រឹក្សា

+ លោក **គ្រីស ម៉ាឡយ** តំណាងនយោជកចំរុះរដ្ឋ - ឯកជន ទីប្រឹក្សា

ប្រការ៣ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានសិទ្ធិបង្កើតក្រុមការងារជាតិ ដែលមានសមាសភាពពីស្ថាប័នឧត្តមសិក្សា អ្នកឯកទេស អង្គការផ្តល់ជំនួយ ដើម្បីអនុវត្តការងារ ។

ប្រការ៤ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានភារកិច្ចដូចតទៅ :

–ជំនួយការអោយរាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍វិស័យឧត្តមសិក្សាក្នុងផែនការសកម្មភាពជាតិ ដើម្បីអោយការវិនិយោគក្នុងវិស័យនេះមានការរីកចំរើនទាន់សភាព – ការណ៍ និងមានប្រសិទ្ធភាព ។

–ដឹកនាំ ត្រួតពិនិត្យ កែលំអផែនការសកម្មភាពជាតិ ដែលរៀបចំឡើង ដោយក្រុមការងារជាតិ ដើម្បីដាក់ជូនសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

ប្រការ៥ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា ត្រូវចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

ប្រការ៦ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សាមានសិទ្ធិប្រើប្រាស់ត្រាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីសំរួលការងារ ។

ប្រការ៧ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានអាណត្តិ ១៨ខែ ។

ប្រការ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងផែន

ការ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បណ្តាស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ; ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ០៤ សសរ

ស្តីពីការបង្កើតក្រុមការងារសំរាប់សំរួលការ

ដោះស្រាយឧបត្ថម្ភដល់បងប្អូនភ្ញាក់រលឹកនៅក្នុងតំបន់ឱ្យវ៉ាល់

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ស្តីពីការបង្កើតអង្គភាពសសំរាប់សំរបសំរួលបញ្ហាកងទ័ពរំសាយ និង សមាហរ័ណកម្មក្នុងសង្គមជាតិនូវអតីតទាហានខ្មែរក្រហម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៥
- ផ្អែកតាមភាពចាំបាច់ចំពោះមុខ

សំរេច

ប្រការ ១ : បង្កើតក្រុមការងារមួយសំរាប់សំរបសំរួលការដោះស្រាយឧបត្ថម្ភដល់បងប្អូនភ្ញាក់រលឹក នៅក្នុងតំបន់ឱរ៉ាល់ ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុល សាម្បឿន** នាយអគ្គសេនាធិការរង ប្រធាន

២–ឯកឧត្តម **អ៊ុច ឡេឿន** អភិបាលរងទី ១ ខេត្តកំពង់ស្ពឺ អនុប្រធានអចិន្ត្រៃយ៍

៣–លោកឧត្តមសេនីយ៍ត្រី **សុខ ផល** មេបញ្ជាការរងយោធភូមិភាគទី ៣ អនុប្រធាន

៤–លោកឧត្តមសេនីយ៍ត្រី **ប្រាក់ សុវណ្ណា** មេបញ្ជាការកងពលធំលេខ ១ អនុប្រធាន

៥–លោក **ហេង រាម** សមាជិក

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលខេត្តកំពង់ស្ពឺ ព្រមទាំងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

នៅភ្នំពេញរាជធានី , ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ០៥ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_យោងតាមការចាំបាច់

សំរេច

ប្រការ ១ : ក្នុងរយៈពេលដែលឯកឧត្តម **អ៊ឹង គៀត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន ត្រូវអញ្ជើញទៅព្យាបាលរោគនៅឯបរទេស ចាប់ពី ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦ ការងារប្រចាំថ្ងៃរបស់ក្រសួងសាធារណការ នឹងដឹកជញ្ជូនត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **យូ ហុកគ្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជារដ្ឋមន្ត្រី ក្រសួងសាធារការ និងដឹកជញ្ជូនស្តីទី រហូតដល់ពេលឯកឧត្តម **អ៊ឹង គៀត** អញ្ជើញត្រឡប់មកមាតុភូមិវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង សាមីខ្លួនត្រូវបានទទួលបន្ទុកអនុវត្តភារកិច្ចនេះរៀងខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ការងារបណ្តាក្រសួង

១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជភ្នំពេញរាជធានី , ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៥៤ ប្រក.សហវ

ស្តីពី

ការបង្កើតក្រុមការងារអចិន្ត្រៃយ៍សំរាប់

ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យនៃអង្គភាពគ្រប់គ្រងគំរោងការ «PMU»

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញប្រកាសលេខ ២៨៩ ប្រ.ក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោងការ ហៅកាត់ « អគគ » (Project Management Unit) ;
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតក្រុមការងារអចិន្ត្រៃយ៍សំរាប់ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ នៃអង្គភាពគ្រប់គ្រងគំរោងការ (PMU) ដែលមានសមាសភាពដូចតទៅ :

ក- អ្នកសំរបសំរួលការងារ (Coordinator) :

១.- លោកស្រី **អា ចៀវសុវណ្ណបុប្ផា**

ខ-អ្នកទទួលខុសត្រូវផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុ : (Responsibility of Accounting and Finance) :

១ - លោក អ៊ឹម្ស ឈឿន អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ជាប្រធានគណនេយ្យ និង ហិរញ្ញវត្ថុផ្នែកទី១,

២ - លោក ជាវ ខ៊ុកចូវ អនុប្រធាននាយកដ្ឋានរបបគណនេយ្យជាប្រធានគណនេយ្យ និង ហិរញ្ញវត្ថុផ្នែកទី ២ ,

គ - ផ្នែករដ្ឋបាល :

១ - លោក ជាវី ចេតនា មន្ត្រីរាជការនៅការិយាល័យសិក្សាស្រាវជ្រាវ និង សម្របសម្រួលរតនាគារជាតិ

ឃ - ប្រធានផ្នែក :

១ - លោក សំ បរម មន្ត្រីអធិការកិច្ចនៅនាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ ជាប្រធានផ្នែកទី ១ ,

២– លោក យូ គិរម្យ មន្ត្រីរាជការនៅនាយកដ្ឋានថវិកាជាប្រធានផ្នែកទី ២ ,

ង - មន្ត្រីរាជការនៅផ្នែកទី ១

១ - លោក ខន្ធ ម៉ុនឥន្ទ្រាខុន មន្ត្រីរាជការនៅការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ,

២ - លោក ម៉ែន ធីរុទ្ធ មន្ត្រីរាជការនៅការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ,

៣ - លោក គីម សុផល មន្ត្រីរាជការនៅការិយាល័យពាណិជ្ជកម្ម នៃនាយកដ្ឋានហិរញ្ញកិច្ច ,

៤ - លោក ទង់ ពេជ្រ អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ ,

ច–មន្ត្រីរាជការនៅផ្នែកទី ២

១ - លោក **យិន សុតី** មន្ត្រីរាជការនៅអង្គភាពមន្ទីរ ,

២ - លោក **សេខ ម៉ុនលី** មន្ត្រីហិរញ្ញកិច្ច ,

៣- លោក **ជេត សំរឿន** មន្ត្រីអធិការកិច្ច ,

៤ - លោក **ឡាច ម៉ាន** មន្ត្រីរាជការនៅការិយាល័យសិក្សាស្រាវជ្រាវ និង សម្របសម្រួលធនាគារជាតិ ។

ប្រការ ២ : ក្រុមការងារនេះ មានការិយាល័យបំពេញការងារស្ថិតនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៣ : ក្រុមការងារនេះ ជាជំនួយការអោយអង្គភាពគ្រប់គ្រងគំរោងការ « PMU » ដើម្បីអនុវត្តនូវភារៈកិច្ចដូចតទៅ ÷

- តាមដាន និង ត្រួតពិនិត្យជាអចិន្ត្រៃយ៍លើការងារអនុវត្តន៍ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ របស់បណ្តាក្រសួង ;
- ទទួលខុសត្រូវក្នុងការគ្រប់គ្រង Trust Fund ;
- ផ្សព្វផ្សាយ និង ជួយបំពាក់បំប៉នមុខជំនាញអោយដល់អង្គភាពរៀបចំគំរោង "PPU" របស់បណ្តាក្រសួងដែលត្រូវគ្រប់គ្រង World Bank Loan ;
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារអនុវត្ត ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យក្នុងក្របខ័ណ្ឌ Trust Fund និង World Bank Loan របស់បណ្តាក្រសួង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានចំណុះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង មន្ត្រីដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសនេះ ។

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៥៨ ប្រក.សហវ.ធរ

ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន *Indochine Insurance Union*

ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤ - ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម ០១៩៦ - ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីការបង្កើតអាជីវកម្មធានារ៉ាប់រង ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ១៣ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការគ្រប់គ្រងអាជីវកម្មធានារ៉ាប់រង ។
- បានឃើញសេចក្តីជូនដំណឹងលេខ ១៥០៣ សជណ.ពហ របស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩២ ស្តីពីការអនុញ្ញាតជាគោលការណ៍អោយក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ចាប់ដំណើរការអាជីវកម្មដោយផ្ទាល់ខ្លួនឯងចាប់ពីដើមត្រីមាសទី ៤ ឆ្នាំ ១៩៩២ តទៅ ។
- តាមសំណើរបស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន Indochine Insurance Union "IIU" ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា « កាមិនកូ » ក្នុងការធ្វើសកម្មភាពលើវិស័យធានារ៉ាប់រងទូទៅនៅព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ក្រុមហ៊ុន Indochine Insurance Union "IIU" ត្រូវបង់ប្រាក់ធានារ៉ាប់រងតំកល់ទុកនៅធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១២.៥០០.០០០,០០ រៀល (ដប់ពីរលានប្រាំសែនរៀល) ។

ប្រការ ៣ : ក្រុមហ៊ុន Indochine Insurance Union ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមតួនាទីជាភ្នាក់ងាររបស់ « កាមិនកូ » ការអនុញ្ញាតនេះ នឹងត្រូវដកហូតវិញគ្រប់ពេលក្នុងករណីដែលក្រុមហ៊ុន Indochine Insurance Union អនុវត្តមិនបានត្រឹម ត្រូវតាមកិច្ចព្រមព្រៀងក្នុងការប្រតិបត្តិនូវតួនាទីជាភ្នាក់ងាររបស់ « កាមិនកូ » ។

ប្រការ ៤ : ការអនុញ្ញាតិនេះផ្តល់ជូនសំរាប់រយៈពេល ០១ ឆ្នាំ ប៉ុន្តែអាចបន្តទៅទៀតបានប្រសិនបើពិនិត្យឃើញថាក្នុងឋានៈជាភ្នាក់ងាររបស់ « កាមិនកូ » ក្រុមហ៊ុន Indochine Insurance Unionអនុវត្តការកិច្ចបានល្អ និង ត្រឹមត្រូវតាមកិច្ចព្រមព្រៀង ។

ប្រការ ៥ : ការអនុញ្ញាតនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៤១ គរ.ប្រក

អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd

ធ្វើប្រតិបត្តិការរុករកធនធានរ៉ែនៅតំបន់ត្បូងដែក ខេត្តព្រះវិហារ

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែនៅតំបន់ភ្នំដែក ខេត្តព្រះវិហារ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៤
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតស្វែងរុករកធនធានរ៉ែរបស់ក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. មានអាស័យដ្ឋាន ផ្ទះលេខ ៣២០ មហាវិថីកម្ពុជាក្រោម រាជធានីភ្នំពេញ ធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែនៅតំបន់ ភ្នំដែក ខេត្តព្រះវិហារ លើផ្ទៃដី ២១៦ គីឡូម៉ែត្រក្រឡា មានកូអរដោណេដូចតទៅ ÷

ចំណុច	ខ្សែរយៈបណ្តោយ	ខ្សែរយៈទទឹង
A	104° 55'00"E	13° 23'3"N
B	105° 05'00"E	13° 23'3"N
C	105° 05'00"E	13° 16'50"N
D	104° 55'00"E	13° 16'50"N

ប្រការ២ : ក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ត្រូវដំណើរការងារស្វែង រុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានាអនុវត្តតាមបច្ចេកទេសភូគព្ភសាស្ត្រ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃដល់ថ្ងៃទី ២៣ មីនា ១៩៩៨ ។ ផុតកំណត់នេះ ក្រុមហ៊ុន ត្រូវដាក់ពាក្យសុំការអនុញ្ញាតបធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានល័ក្ខខ័ណ្ឌ ។

ប្រការ ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ - រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ព្រះវិហារ និង ប្រធានក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរ:

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៤២ គរ.ប្រក
អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd
ធ្វើប្រតិបត្តិការរុករកធនធានរ៉ែនៅតំបន់ក្រវ៉ា ខេត្តកំពង់ធំ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែនៅតំបន់ក្រវ៉ា ខេត្តកំពង់ធំ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៤
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតស្វែងរុករកធនធានរ៉ែរបស់ក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. មានអាស័យដ្ឋានផ្ទះលេខ ៣២០ មហាវិថីកម្ពុជាក្រោម រាជធានីភ្នំពេញធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែនៅតំបន់ក្រវ៉ា ខេត្តកំពង់ធំ លើផ្ទៃដី ១៩៨ គីឡូម៉ែត្រក្រឡា មានកូអរដូណេដូចតទៅ ÷

ចំណុច	ខ្សែរយៈបណ្តោយ	ខ្សែរយៈទទឹង
A	105° 11'37"E	12° 31'44"N
B	105° 21'32"E	12° 31'44"N
C	105° 21'32"E	12° 25'16"N
D	105° 11'37"E	12° 25'16"N

ប្រការ ២ : ក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ត្រូវដំណើរការងារស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានាអនុវត្តតាមបច្ចេកទេសភូគព្ភសាស្ត្រ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃដល់ថ្ងៃទី ២៣ មីនា ១៩៩៨ ។ ផុតកំណត់នេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំការអនុញ្ញាតិធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានលក្ខខ័ណ្ឌ ។

ប្រការ ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ - រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត កំពង់ធំ និង ប្រធានក្រុមហ៊ុន DELCOM CAMBODIA Pte.Ltd. ត្រូវទទួលអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

* * *

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៧២/៩៦ ពប.មពប្រក
អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ ឈោសិប្ប ២ ខ្លូ
បោះពុម្ពចែកផ្សាយឡើងវិញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស

អោយប្រើតាមព្រះរាជក្រមលេខ : នស.រកម.០៨៩៥.០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

– បានឃើញសំណើបោះពុម្ពផ្សាយទស្សនាវដ្ដីឈ្មោះ រណសិរ្ស ២ ធ្នូ របស់លោក **ខៀវ គាន** ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្ដីឈ្មោះ រណសិរ្ស ២ ធ្នូ បោះពុម្ពចែកផ្សាយឡើងវិញ ដោយមានលោក **ខៀវ គាន** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៣៨៩ ផ្លូវ ស៊ីសុវត្ថិ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្ដូរចំណុចណាមួយក្នុងអត្ត សញ្ញាណប័ណ្ណ នៃទស្សនាវដ្ដីរបស់ខ្លួនត្រូវជូនដំណឹងជាមុន ១០ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្ដីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹម សារ អត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ ប្រពៃណីល្អនិង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ទស្សនាវដ្ដីចំនួន ៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស អំពីសេចក្ដីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង លោក **ខៀវ គាន** ចាងហ្វាងការផ្សាយ ត្រូវអនុវត្តនូវប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៧៥ ព.ម បសន.ប្រក
អនុញ្ញាតអោយលោក ហួន សោភ័ណ្ណារិទ្ធិ
បើកអាជីវកម្មទូរទស្សន៍ខ្សែកាប

រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យលើសំណើសុំ អនុញ្ញាតច្បាប់បើកអាជីវកម្ម ទូរទស្សន៍ខ្សែកាបរបស់លោក **ហួន សោភ័ណ្ណារិទ្ធិ** ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ហួន សោភ័ណ្ណារិទ្ធិ** បច្ចុប្បន្ននៅផ្ទះលេខ ២៨០ ក្រុមទី ៤ ផ្លូវលេខ ១៩ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ បើកអាជីវកម្មទូរទស្សន៍ខ្សែកាប សំរាប់បន្តជាវអោយអតិថិជននៅទីរួមខេត្តពោធិសាត់ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ទូរទស្សន៍ខ្សែកាបនេះ ត្រូវគោរពតាមកិច្ចសន្យា និង ច្បាប់បញ្ញត្តិ បទបញ្ជា ឬ សេចក្តីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា , ព្រមទាំងទទួលការណែនាំផ្ទាល់ពីមន្ទីរព័ត៌មានខេត្ត ពោធិសាត់ ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការទី ២ សាមីខ្លួននឹងត្រូវទទួលទោសតាម ច្បាប់ជាធរមាននៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយសោតទស្សន៍ នៃ អគ្គនាយកដ្ឋាន រដ្ឋបាលហិរញ្ញវត្ថុ មន្ទីរព័ត៌មានខេត្តពោធិសាត់ និង សាមីខ្លួនត្រូវអនុវត្តនូវប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អឿន មូលី

* * *

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៩០ អយក.ប្រ.ក

ស្តីពីផ្លាស់សាលាឧបសម្ព័ន្ធ អំពិលក្រាង

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ - ៧ - ១៩៩៤

– បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ - ១១ - ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ

– បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ - ១០ - ១៩៨៦ ស្តីពីការកំណត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា

– បានពិនិត្យលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ

លេខ ៦៥ អយុមនុ. ចុទម្ម. ចុះថ្ងៃទី ០២ - ០១ - ១៩៨៦

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្តបន្ទាយមានជ័យ ផ្តាច់សាលាបឋមសិក្សាអំពិលព្រង់ ឧបសម្ព័ន្ធសាលាបឋមសិក្សាស្រះថៃង ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មកជា « សាលាបឋមសិក្សា អំពិលព្រង់ » ពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ១៩៨៦ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាអំពិលព្រង់ ត្រូវដឹកនាំដោយនាយក ១ រូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់បឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត បន្ទាយមានជ័យ ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុកស្វាយចេក នាយកសាលាបឋមសិក្សា ស្រះថៃង នាយកសាលាបឋមសិក្សា អំពិលព្រង់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៨៦

ប្រកាសលេខ ១៩៧ អយក. ប្រក

ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធមកជាសាលាពេញលក្ខណៈ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ - ៧ - ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ - ១១ - ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ - ១០ - ១៩៨៦ ស្តីពីការកំនត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ លេខ ៦៤ អយក៦. ចទម ចុះថ្ងៃទី ០២ - ០១ - ១៩៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្តបន្ទាយមានជ័យ ផ្តាច់ :

១-សាលាឧបសម្ព័ន្ធ ម៉ៅ ចេញពី សាលាបឋមសិក្សា ផ្គាំ មកជាសាលាបឋមសិក្សា ម៉ៅ ពេញលក្ខណៈវិញ ។

២-សាលាឧបសម្ព័ន្ធ យាងវៀន ចេញពី សាលាបឋមសិក្សា ផ្គាំ មកជាសាលាបឋមសិក្សាយាងវៀនពេញលក្ខណៈវិញ ។

ប្រការ ២ : សាលាបឋមសិក្សា ដូចមានរាយនាមខាងលើ ត្រូវដឹកនាំដោយនាយក ១ រូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋាន ក្របខ័ណ្ឌសំរាប់ សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និង នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មន្ត្រីយុវសិក្សា ប្រធានមន្ទីរ អប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុកស្វាយចេក នាយកសាលាបឋមសិក្សា ម៉ៅ និង នាយកសាលាបឋមសិក្សា យាងវៀន មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១២០ ស.នបដ

ស្តីពីការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យសុខាភិបាលស្រុក

_បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញសារាចរលេខ ៨៥ ស.កកទ ចុះថ្ងៃទី ២៥_៧_១៩៩៥ របស់ក្រសួងសុខាភិបាលស្តីពីការកសាង និង អនុវត្តផែនការគ្របដណ្តប់សុខាភិបាលស្រុក_ឃុំ

_បានឃើញសារាចរលេខ ១៩០ ចុះថ្ងៃទី ១៣_១២_១៩៩៤របស់ក្រសួងសុខាភិបាលស្តីពីការតែងតាំងប្រធានការិយាល័យសុខាភិបាលស្រុក

-បានឃើញលិខិត ២១៦២ ចុះថ្ងៃទី ០២-៩-១៩៩៥ របស់ក្រសួងសុខាភិបាល ស្តីពីតួនាទី និងភារកិច្ចរបស់ប្រធាន និង អនុប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង

-ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ដាក់អោយអនុវត្តក្នុងលក្ខណៈសាកល្បងនូវរចនាសម្ព័ន្ធរដ្ឋបាល និងបច្ចេកទេស នៅតាមស្រុក ចំនួន ១២ ដូចខាងក្រោម ចាប់ពីឆ្នាំ ១៩៩៦ តទៅ :

១-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកមោងឫស្សី ខេត្តបាត់ដំបង

២-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកឧត្តុង្គ ខេត្តកំពង់ស្ពឺ

៣-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកបាកាន ខេត្តពោធិសាត់

៤-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែករមាសហែកខេត្តស្វាយរៀង

៥-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកអ្នកលឿង ខេត្តព្រៃវែង

៦-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកព្រៃឈរ ខេត្តកំពង់ចាម

៧-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកសូត្រនិគម ខេត្តសៀមរាប

៨-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យបង្អែកស្អាង ខេត្តកណ្តាល

៩-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យខេត្តរតនគីរី ខេត្តរតនគីរី

១០-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

១១-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យខេត្តកំពត ខេត្តកំពត

១២-ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យរាជធានីភ្នំពេញ រាជធានីភ្នំពេញ

ប្រការ ២: ស្រុកប្រតិបត្តិនីមួយ ៗ ត្រូវមាន ÷

-ប្រធានការិយាល័យសុខាភិបាលស្រុក ១ រូប ដែលត្រូវបំពេញភារកិច្ចដូច ឧបសម្ព័ន្ធទី៣ជូនភ្ជាប់ ។

- អនុប្រធានការិយាល័យសុខាភិបាលស្រុក ១ រូប ទទួលបន្ទុកជាប្រធានមន្ទីរពេទ្យបង្អែក ដែលត្រូវបំពេញភារកិច្ចដូចឧបសម្ព័ន្ធទី ៥ ជូនភ្ជាប់ ។

- អនុប្រធានការិយាល័យសុខាភិបាលស្រុក ១ រូប ឬ ២ រូប ទទួលបន្ទុកគ្រប់គ្រងមណ្ឌលសុខភាពដែលត្រូវបំពេញភារកិច្ចដូចឧបសម្ព័ន្ធទី ៤ ជូនភ្ជាប់ ។

ប្រការ ៣ : មន្ទីរពេទ្យបង្អែកមានអនុប្រធានមួយរូបសំរាប់ជួយប្រធាន ក្នុងដំណើរការប្រចាំថ្ងៃរបស់មន្ទីរពេទ្យ ។

ប្រការ ៤ : ស្រុកដែលនៅក្នុងតំបន់ទទួលខុសត្រូវរបស់មន្ទីរពេទ្យខេត្ត–ក្រុង–រាជធានី ឬ មន្ទីរពេទ្យមជ្ឈិម ពុំចាំបាច់មានអនុប្រធានការិយាល័យសុខាភិបាលស្រុក ទទួលបន្ទុកជាប្រធានមន្ទីរពេទ្យបង្អែកឬអនុប្រធានមន្ទីរពេទ្យដូចដែលបាន ចែងក្នុងប្រការ ២ និង ប្រការ ៣ ឡើយ ។

ប្រការ ៥ : មន្ទីរពេទ្យខេត្ត–ក្រុង–រាជធានី ដែលមានទីតាំងនៅទីរួម ខេត្ត–ក្រុង–រាជធានី ត្រូវបំពេញភារកិច្ចជាមន្ទីរពេទ្យបង្អែកដើម្បីគ្របដណ្តប់តំបន់ទទួលខុសត្រូវ របស់ស្រុកប្រតិបត្តិមួយ ប៉ុន្តែមន្ទីរពេទ្យទាំងនេះត្រូវនៅក្រោមការគ្រប់គ្រង ផ្ទាល់របស់មន្ទីរសុខាភិបាលខេត្ត–ក្រុង–រាជធានី ទាំងផ្នែករដ្ឋបាលទាំង ផ្នែក បច្ចេកទេស ។

ប្រការ ៦ : មន្ទីរពេទ្យមជ្ឈិមអាចគ្របដណ្តប់តំបន់ទទួលខុសត្រូវស្រុកប្រតិបត្តិ ប៉ុន្តែត្រូវ នៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងសុខាភិបាល ទាំងផ្នែករដ្ឋបាល ទាំង ផ្នែកបច្ចេកទេស ។

ប្រការ ៧ : មន្ទីរសុខាភិបាលខេត្ត–ក្រុង–រាជធានី ត្រូវណែនាំជំរុញមន្ទីរពេទ្យខេត្ត– ក្រុង រាជធានី អោយសហការជួយគាំទ្រដល់ការអភិវឌ្ឍន៍ និង ការអនុវត្តន៍ផែន ការសុខាភិបាលស្រុកប្រតិបត្តិពាក់ព័ន្ធ ។ ប្រធាននាយកដ្ឋានសុខាភិបាល ត្រូវណែនាំជំរុញមន្ទីរពេទ្យមជ្ឈិម អោយសហការជួយគាំទ្រដល់ផែនការ អភិវឌ្ឍន៍ និង ការអនុវត្តន៍ផែនការសុខាភិបាលស្រុកប្រតិបត្តិពាក់ព័ន្ធ ។

ប្រការ ៨: ការិយាល័យសុខាភិបាលស្រុកមានពីរផ្នែក ៖

–ផ្នែកបច្ចេកទេស

–ផ្នែករដ្ឋបាល ស្ថិតិផែនការ និង ហិរញ្ញវត្ថុ (រដ្ឋបាល ស្ថិតិផែនការ គណនេយ្យនិងហិរញ្ញវត្ថុ ជួសជុលថែទាំ) ។

ប្រការ ៩: ស្រុកប្រតិបត្តិនីមួយៗត្រូវមានគណៈកម្មការគ្រប់គ្រងមួយដែលមានការចូលរួមពី ៖

–ប្រធានការិយាល័យសុខាភិបាលស្រុក

–តំណាងអាជ្ញាធរស្រុក ១ រូប

–តំណាងសេវាមន្ទីរពេទ្យមួយរូបជ្រើសរើសក្នុងចំណោមមន្ត្រីសុខាភិបាលក្នុងមន្ទីរ ពេទ្យបង្អែក

–តំណាងមណ្ឌលសុខភាព ១ រូប ជ្រើសរើសក្នុងចំណោមប្រធានមណ្ឌលសុខភាព

–តំណាងសហគមន៍ ១ រូប ជ្រើសរើសក្នុងចំណោមប្រជារាស្ត្រ ឬ ព្រះសង្ឃដែលមានការ ទុកចិត្តពីប្រជារាស្ត្រ

ប្រការ១០ : ស្រុកប្រតិបត្តិអាចមានអង្គការលេខតាមគំរូណាមួយក្នុងគំរូទាំងពីរយ៉ាង ដូចឧបសម្ព័ន្ធទី ១និង ទី ២ ជូនភ្ជាប់ដោយយោងទៅតាមន័យដូចចែងក្នុងប្រការ ២–៨ ខាងដើម ។

ប្រការ១១ : ស្រុកប្រតិបត្តិដែលពុំមានចែងក្នុងប្រការ ១ អាចចាប់ផ្តើមអនុវត្តរចនាសម្ព័ន្ធដូចដែលបានចែងក្នុងប្រការ ២–១០ បានលុះត្រាតែមានការអនុញ្ញាតិពីក្រសួងសុខាភិបាល។ អង្គការលេខ សុខាភិបាលស្រុកដែលលើកស្នើមកក្រសួងសុខាភិបាល ត្រូវមានបញ្ជាក់ឈ្មោះស្រុកប្រតិបត្តិ ឈ្មោះមណ្ឌលសុខភាពឈ្មោះមន្ទីរពេទ្យបង្អែក ។

ប្រការ១២: ខុទ្ទកាល័យក្រសួងសុខាភិបាល នាយកដ្ឋានសុខាភិបាល មន្ទីរសុខាភិបាលខេត្ត–ក្រុងពាក់ព័ន្ធ ត្រូវទទួលភារៈរៀង ៗ ខ្លួនអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
វេជ្ជ ឈា ថាំង

* * *

ឧបសម្ព័ន្ធទី ១

ស្រុកប្រតិបត្តិដែលមិនមែនទទួលខុសត្រូវដោយមន្ទីរខេត្ត–ក្រុង រាជធានី ឬ មជ្ឈិម

គំរូទី ១ : អង្គការលេខសុខាភិបាលស្រុក :..



* ស្រុកប្រតិបត្តិដែលមានចំនួនមណ្ឌលសុខភាពលើសពី ១៥ អាចមានអនុប្រធានសុខាភិបាលស្រុក ២ រូប សំរាប់ទទួលបន្ទុកមណ្ឌលសុខភាព ។

ឧបសម្ព័ន្ធទី ២

ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យខេត្ត–ក្រុងរាជធានី ដែលមានទីតាំងនៅទីរួមខេត្ត– ក្រុងរាជ ធានីភ្នំពេញ ឬ មជ្ឈឹម

គំរូទី ១ : អង្គការលេខសុខាភិបាលស្រុក :...



* ស្រុកប្រតិបត្តិដែលមានចំនួនមណ្ឌលសុខភាពលើសពី ១៥ អាចមានអនុប្រធាន

ការិយាល័យ ២ ឬ សំរាប់ទទួលបន្ទុកមណ្ឌលសុខភាព ។

ឧបសម្ព័ន្ធទី ៣ របស់ប្រកាសលេខ ១២០ សនបន ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

តួនាទី និង ភារកិច្ច

ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ

តួនាទី : ប្រធានការិយាល័យសុខាភិបាលស្រុក

កាលបរិច្ឆេទ : ខែ មីនា ឆ្នាំ ១៩៩៦

សង្ខេបភារកិច្ច:

- ធានាការអភិវឌ្ឍន៍អនុវត្តន៍ និង វាយតំលៃផែនការសុខាភិបាលស្រុកប្រតិបត្តិដោយផ្អែកតាមគោលនយោបាល និង យុទ្ធសាស្ត្រសុខាភិបាលជាតិនិងតាមការណែនាំរបស់មន្ទីរ សុខាភិបាលខេត្ត ។
- គ្រប់គ្រងការផ្តល់សេវាសុខាភិបាលសាធារណៈ និង តាមដានការអនុវត្តន៍សេវាសុខាភិបាលឯកជន ។

ភារកិច្ចលំអិត :

- ធានាធ្វើផែនការនិង ដាក់អោយដំណើរការនូវសំណុំសកម្មភាពអប្ប បរមានៅមណ្ឌលសុខភាព និង សំណុំសកម្មភាពបង្គ្រប់នៅមន្ទីរពេទ្យបង្អែក ។
- គ្រប់គ្រងសកម្មភាព និង ធនធានសុខាភិបាលទូទាំងស្រុកប្រតិបត្តិ ។
- ធ្វើផែនការបណ្តុះបណ្តាលបន្ថែម និង ការបណ្តុះបណ្តាលបន្តសំរាប់បុគ្គលិកមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែក ។
- ធានាការគ្រប់គ្រងថវិកា និងធនធានហិរញ្ញវត្ថុសំរាប់សុខាភិបាលស្រុកប្រតិបត្តិប្រព័ន្ធពត៌មាន និងគាំទ្រកិច្ចការ វិស័យសុខាភិបាលផង ។
- សំរបសំរួល និងតាមដានវិស័យសុខាភិបាលឯកជន ក្នុងការអនុវត្តនីតិក្រមវេជ្ជសាស្ត្រ និសថសាស្ត្រ ។
- អន្តរាគមន៍ជាបន្ទាន់ចំពោះជំងឺរាតត្បាតនានា ។
- ធានាការអនុវត្តន៍កម្មវិធីជាតិតាមរយៈការផ្តល់សេវារួមបញ្ចូលគ្នានៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។
- ដឹកនាំសកម្មភាពគណៈកម្មការគ្រប់គ្រងស្រុកប្រតិបត្តិ ។

ទំនាក់ទំនងការងារ:

- ទទួលខុសត្រូវចំពោះមុខប្រធានមន្ទីរសុខាភិបាលខេត្ត ។
- ទទួលខុសត្រូវផ្ទាល់លើអនុប្រធានការិយាល័យសុខាភិបាលស្រុក និងប្រធានផ្នែកបច្ចេកទេសរដ្ឋបាលស្ថិតិផែនការនិងហិរញ្ញវត្ថុ និង ដោយប្រយោលលើបុគ្គលិកសុខាភិបាលទូទាំងស្រុកប្រតិបត្តិ ។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងវិស័យដទៃតាមរយៈគណៈកម្មការគ្រប់គ្រងស្រុកប្រតិបត្តិ ឬ តាមរយៈយន្តការដទៃទៀត ។
- ក្នុងករណីស្រុកប្រតិបត្តិដែលគ្របដណ្តប់ដោយមន្ទីរពេទ្យ ខេត្ត–ក្រុង ឬ រាជធានីត្រូវសហការជាមួយមន្ទីរពេទ្យទាំងនោះ ដើម្បីធានាគុណភាពសេវាសុខាភិបាលទូទាំងស្រុកប្រតិបត្តិ ។
- សហការជាមួយការិយាល័យស្រុកជិតខាង ស្តីពីផែនការគ្របដណ្តប់សុខាភិបាល ។
- សហការជិតស្និទ្ធជាមួយអាជ្ញាធរស្រុក–ឃុំ និងការិយាល័យនានាជុំវិញស្រុកក្នុងការធានាសុខមាលភាពជូនប្រជារាស្ត្រ និង អន្តរាគមន៍ចំពោះគ្រោះមហន្តរាយអាសន្ននានា ។
- សហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរស្រុក និងសុំយោបល់ស្តីពីការអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រក្រសួងសុខាភិបាលដូចជាផែនការសុខាភិបាលខេត្ត ។

ឧបសម្ព័ន្ធទី ៤ របស់ប្រកាសលេខ ១២០ ស.នបន ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

តួនាទី និង ភារកិច្ច

អនុប្រធានការិយាល័យសុខាភិបាលស្រុក

ទទួលបន្ទុកមណ្ឌលសុខភាព

តួនាទី: អនុប្រធានការិយាល័យទទួលបន្ទុកមណ្ឌលសុខភាព

កាលបរិច្ឆេទ : ខែ មីនា ឆ្នាំ ១៩៩៦

សង្ខេបភារកិច្ច:

- ទទួលខុសត្រូវក្នុងការផ្តល់សេវាមណ្ឌលសុខភាព តាមចំនួនដែលកំណត់ដោយប្រធានការិយាល័យសុខាភិបាលស្រុក ។
- ទទួលខុសត្រូវលើអន្តរាគមន៍បន្ទាន់ចំពោះរាល់ជំងឺរាតត្បាតដែលកើតមាន ។

ភារកិច្ចលំអិត:

- ធានាការការកសាងអនុវត្តន៍ និងវាយតំលៃផែនការសេវាមណ្ឌលសុខភាពតាមរយៈសិណ្ណុំសកម្មភាពអប្បបរមា ។
- គ្រប់គ្រងសកម្មភាព និង ធនធានក្នុងមណ្ឌលសុខភាព ។
- ចុះត្រួតពិនិត្យណែនាំ និង បណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាព និងភ្នាក់ងារសុខភាពសហគមន៍ ។
- ធានាការអនុវត្តន៍កម្មវិធីតាមរយៈការផ្តល់សេវាសុខាភិបាល រួមបញ្ចូលគ្នាពេញលេញនៅមណ្ឌលសុខភាពក៏ដូចជាក្នុងសហគមន៍ ។
- គ្រប់គ្រងប្រព័ន្ធពត៌មានសុខាភិបាលសំរាប់មណ្ឌលសុខភាព រួមទាំងគាំទ្រការងារស្រាវជ្រាវនានាក្នុងសហគមន៍ផង ។

ទំនាក់ទំនងការងារ:

- ទទួលខុសត្រូវចំពោះមុខប្រធានការិយាល័យសុខាភិបាលស្រុក ។
- ទទួលខុសត្រូវលើប្រធានមណ្ឌលសុខភាព តាមចំនួនដែលកំណត់ដោយប្រធានការិយាល័យសុខាភិបាលស្រុក ។
- សហការជាមួយអាជ្ញាធរមូលដ្ឋានស្រុក_ឃុំ និងវិស័យនានាក្នុងការធានាសុខមាលភាពជូនប្រជារាស្ត្រ និងអន្តរាគមន៍ចំពោះគ្រោះមហន្តរាយ ។
- សហការជាមួយប្រធានមន្ទីរពេទ្យបង្អែកក្នុងការអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែកដែលឆ្លើយតប នឹងតំរូវការគាំទ្រមណ្ឌលសុខភាព និងប្រជារាស្ត្រក្នុងស្រុក ។

* * *

ឧបសម្ព័ន្ធទី ៥ របស់ប្រកាសលេខ ១២០ ស.នបន ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

តួនាទី និង ភារកិច្ច

អនុប្រធានការិយាល័យសុខាភិបាលស្រុក
ទទួលបន្ទុកជាប្រធានមន្ទីរពេទ្យបង្អែក

តួនាទី: ប្រធានមន្ទីរពេទ្យបង្អែក

កាលបរិច្ឆេទ : ខែ មីនា ឆ្នាំ ១៩៩៦

សង្ខេបភារកិច្ច:

- ទទួលខុសត្រូវក្នុងការផ្តល់ និង គ្រប់គ្រងសេវាមន្ទីរពេទ្យបង្អែក ។
- ទទួលខុសត្រូវក្នុងការជួយគាំទ្របច្ចេកទេសដល់មណ្ឌលសុខភាព តាមរយៈការបណ្តុះបណ្តាល សហការក្នុងការពិនិត្យណែនាំ និងបទអន្តរាគមន៍បន្ទាន់ចំពោះជំងឺភគព្យាត ។

ភារកិច្ចលំអិត:

- ធានាការធ្វើផែនការដាក់អោយដំណើរការ និងវាយតំលៃនូវសំណុំសកម្មភាពបង្គ្រប់នៅមន្ទីរពេទ្យបង្អែក ។
- គ្រប់គ្រងសកម្មភាព និង ធនធានក្នុងមន្ទីរពេទ្យបង្អែក ។
- ជួយសហការគាំទ្រដល់ការអភិវឌ្ឍន៍ និងដំណើរការមណ្ឌលសុខភាពតាមរយៈការចុះត្រួតពិនិត្យណែនាំ ឬ បណ្តុះបណ្តាល ។
- គ្រប់គ្រងថវិកា និង ធនធានហិរញ្ញវត្ថុសំរាប់មន្ទីរពេទ្យបង្អែក ។
- គ្រប់គ្រងប្រព័ន្ធពត៌មានសុខាភិបាលសំរាប់មន្ទីរពេទ្យបង្អែក និងជួយគាំទ្រការស្រាវជ្រាវវេជ្ជសាស្ត្រ និសថសាស្ត្រ ។
- សហការក្នុងអន្តរាគមន៍បន្ទាន់ចំពោះជំងឺភគព្យាត ។
- ធានាការអនុវត្តន៍កម្មវិធីសុខាភិបាលជាតិនានា តាមរយៈការផ្តល់សេវារួមបញ្ចូលគ្នានៅមន្ទីរពេទ្យបង្អែក ។

ទំនាក់ទំនងការងារ:

- ទទួលខុសត្រូវចំពោះមុខប្រធានការិយាល័យសុខាភិបាលស្រុក ។
- ទទួលខុសត្រូវលើមន្ត្រីរាជការទូទាំងមន្ទីរពេទ្យបង្អែក ។
- ជួយគាំទ្រ ប្រធានការិយាល័យសុខាភិបាលស្រុកទទួលបន្ទុកមណ្ឌលសុខភាពក្នុងការអភិវឌ្ឍន៍ និងអនុវត្តផែនការសេវានៅមណ្ឌលសុខភាព និងសហគមន៍

ព្រមទាំងក្នុងការអន្តរាគមន៍បន្ទាន់ចំពោះជំងឺរាគរូស ។

* * *

៦—ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៦៩ កទ.

ស្តីពីការតែងតាំងជាបណ្តោះអាសន្ន

ចំពោះមន្ត្រីថ្នាក់ការិយាល័យ នៃមន្ទីរទេសចរណ៍ក្រុងកែប

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–យោងប្រកាសលេខ ៨៩៣ កទច ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរ សំរាប់មន្ទីរទេសចរណ៍ក្រុងកែប

–យោងប្រកាសលេខ ០២ កទច. ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការនៃមន្ទីរទេសចរណ៍ក្រុងកែប

–យោងលិខិតលេខ ០១៤ កប. ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ របស់អភិបាលក្រុងកែប និង លិខិតលេខ ០២១ ទចក. ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៦ របស់មន្ទីរទេសចរណ៍ក្រុងកែប ស្តីពីការសុំតែងតាំងមន្ត្រីថ្នាក់ការិយាល័យ

សម្រេច

ប្រការ ១ : តែងតាំងលោក **សុខ ឈាង** ជាប្រធានការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ នៃមន្ទីរទេសចរណ៍ ក្រុងកែប ។

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត–ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ក្រុងកែប និងសាមីខ្លួនត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ថោង ខុន

* * *

៧–ធីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ប្រកាស

ប្រកាសលេខ ១៤៦ សអក. ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន

ឃីព ហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្តមែន

KEEP GOING (H.K) INVESTMENT, LTD

រៀបចំការងារបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

* * *

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

–បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

–បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៥៧ អនក្រ.បក. ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្ដីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ។

–តាមសំណើរបស់ក្រុមហ៊ុន ឃីព ហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្ដមែន

សម្រេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ឃីព ហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្ដមែន មានទីស្នាក់ការស្ថិតនៅផ្ទះលេខ ១៣ និង ១៤ ផ្លូវ ១៦៤ ក្រុមទី ..... សង្កាត់អូរឫស្សីទី ៣ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

មានលោក /លោកស្រី **ជូ ឈួន** សញ្ជាតិកម្ពុជា អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ ៣១៤១៩៩ ភព. ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩១ មានសិទ្ធិពិភាក្សាជាមួយក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ក្នុងការងារបណ្ដុះបណ្ដាល និង បញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ហុងកុង ម៉ាកាវ តៃវ៉ាន់ និង ជប៉ុន ។

ប្រការ ២ : កំណត់អោយក្រុមហ៊ុន ឃីព ហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្ដមែន តំកល់ប្រាក់ធានាចំនួន ៥០.០០០ ដុល្លារ ជាអក្សរ "ហាសិបពាន់ ដុល្លារអាមេរិក" ក្នុងគណនីរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន នៅធនាគារពាណិជ្ជកម្ម ក្រៅប្រទេសស្ថិតនៅផ្ទះលេខ ២៤ ផ្លូវព្រះនរោត្តម សង្កាត់ ផ្សារចាស់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ យ៉ាងយូរបំផុតរយៈពេល ៧ ថ្ងៃ ក្រោយចេញប្រកាស ។ នៅពេលដែលក្រុមហ៊ុននេះ ចាប់ផ្ដើមជ្រើសរើសពលករ ក្រុមហ៊ុនត្រូវយកប្រាក់តំកល់មកបង់អោយគ្រប់ចំនួនមួយរយពាន់ដុល្លារអាមេរិក ។ ផុតការកំណត់នេះបើក្រុមហ៊ុនមិនយកប្រាក់ធានាមកតំកល់គ្រប់ចំនួនទេ ប្រសិទ្ធភាពប្រកាសនេះត្រូវចាត់ទុកជាមោឃៈដោយពេញច្បាប់ ។

ប្រការ ៣ : ក្រុមហ៊ុនត្រូវរៀបចំកិច្ចសន្យាដោយផ្ទាល់រវាងក្រសួងជាមួយក្រុមហ៊ុន និង រវាងក្រុមហ៊ុនជាមួយពលករអោយបានច្បាស់លាស់ និង ត្រឹមត្រូវតាមល័ក្ខខ័ណ្ឌនៃសារាចរណែនាំរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

ប្រការ ៤ : ប្រកាសអនុញ្ញាតនេះ មានសុពលភាពត្រឹមថ្ងៃទី ០១ មីនា ឆ្នាំ ១៩៩៩ ។ ក្រុមហ៊ុន ឃីព ហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្ដមែន ត្រូវធ្វើសំណើជាលាយល័ក្ខអក្សរស្នើសុំធ្វើការពន្យារពេលប្រើប្រាស់ ប្រកាសអនុញ្ញាតបន្តទៅទៀតអោយបាន ២ ខែ

យ៉ាងតិចមុនប្រកាសអនុញ្ញាតអស់សុពលភាព ឬ មួយស្នើសុំរៀបចំប្រកាសថ្មី ។ ក្នុងករណីដែលពិនិត្យឃើញថា ក្រុមហ៊ុន ឃីព ហ្គោអ៊ីង «ហុងកុង» អ៊ិនវេស្ដមែន អនុវត្តផ្ទុយនឹងច្បាប់វិធាននានានៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៥៧ អនក្រ.បក. របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន នឹងចេញប្រកាសផ្អាក ឬ បដិសេធប្រកាសនេះទៅតាមករណីនីមួយ ៗ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ុយ សែម

* * *

៨–ទីស្ដីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៣០ ប.ទ.ប្រ.ក

ស្ដីពីការបញ្ជូនក្របខ័ណ្ឌមន្ត្រី បុគ្គលិក និង រាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យលេខ នសរកត.១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពី ការកែសម្រួលរាជរដ្ឋាភិបាល

–បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦–២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគម –

នាគមន៍

–បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញសេចក្តីសំរេចលេខ ១២៤៤ មស.ក្រខ. ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់រដ្ឋលេខាធិការមុខងារសាធារណៈ

សំរេច

ប្រការ ១ : បញ្ចូលក្របខ័ណ្ឌ មន្ត្រី បុគ្គលិក រាជការ ចំនួន ៥៨ នាក់ អោយទៅបំរើការងារនៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ តាមបណ្តា ខេត្ត– ក្រុង នានា ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៨៦ ដូចមាន រាយនាមខាងក្រោម ÷

១–មន្ទីរប,ទ ខេត្តកណ្តាល :

១–	ទា	ប៊ុនលី	ប្រុស	០៥–៥–៧២
២–	អ៊ុន	នាង	–	០១–០១–៦៧
៣–	ពាក្យ	មុន្នី	–	១១–១២–៧៥
៤–	ឡៅ	សម្បត្តិ	–	០៨–៩–៧៥
៥–	កេង	សុខឃឿន	–	២២–៦–៧៤
៦–	លី	សុខហ្គេច	–	០៩–១០–៦៦
៧–	ហង់	យ៉េង	–	០៥–១២–៧០
៨–	គីម	សារ៉ុម	–	០៩–៦–៦៩
៩–	ហ៊ុល	សុភី	–	១៥–៥–៧២
១០–	សាំង	មុំ	ស្រី	០៩–១១–៧៥
១១–	មាស	គីណាក់	–	២៩–១១–៦៨
១២–	គ្រុយ	សុខា	ប្រុស	២៨–៣–៧៦
១៣–	ញ៉ឹម	ឡាយ	–	០៣–៥–៥០
១៤–	លឹម	លីវ៉ា	–	០២–០២–៧៤
១៥–	តាំង	សារឿន	ស្រី	០៨–៣–៧៥

២– មន្ទីរប,ទ ខេត្តកំពង់ចាម :

១–	ជឹម	ប៊ុនណាន	ប្រុស	០៦–៦–៧៥

២–	សួស	សុផល	–	០១–០១–៧៤
៣–	ឈិត	សម្បត្តិ	–	០៣–៥–៧៦
៤–	អ៊ុក	យុន	–	២៩–៩–៤៨
៥–	ចាន់	សុជាតិ	ស្រី	១០–៩–៧៤
៦–	មួង	សុផាន់	ប្រុស	២០–៣–៥០
៧–	ផាន់	វ៉ាន់ធី	–	២១–៣–៧៣
៨–	ង៉ូវ	គីមឈៀន	–	១០–១០–៦៤
៩–	កុយ	សុវណ្ណ	–	០១–១០–៤៥
១០–	ឆេង	វេង	–	១៦–១១–៧៣
១១–	ម៉ៅ	សុន	–	០៩–៦–៧០

៣– មន្ទីរប,ឧ ខេត្តបាត់ដំបង :

១–	ង៉ាន់	ខេន	ប្រុស	២៤–៤–៧០
២–	ឈាង	វណ្ណៈ	ស្រី	០៥–០២–៧៣
៣–	ពុន	ចាន់រ័ក្ស	ប្រុស	១០–៥–៧៤
៤–	គុជ	កុសល	–	០៦–៧–៧៥
៥–	ព្រឿង	ភិរុណ	–	១៣–៧–៧២

៤– មន្ទីរប,ឧ ខេត្តកំពង់ស្ពឺ :

១–	ជិន	ចាន់ថា	ប្រុស	១៦–៦–៧៣
២–	អ៊ិម	ស៊ីណូ	–	០២–៤–៧១
៣–	កែវ	សំអាត	–	០៣–៣–៥៩
៤–	ឆេង	សុខហៀង	–	១៥–៣–៧៦
៥–	ទី	រឿន	–	០៣–៩–៦៩
៦–	សាន	សារ	–	១០–១១–៧១

៥– មន្ទីរប,ឧ ខេត្តតាកែវ :

១–	យង់	លក្ខណា	ស្រី	០៣–៤–៧២
២–	ប៊ិច	សម្បត្តិ	–	១៥–១២–៥៣
៣–	ម៉េង	ចាន់ធឿន	ប្រុស	០៥–៨–៧៥

៤– ងាញ់ វត្ថា – ០៨–៩–៧២

៥– ស៊ុំ សុខុម – ០៣–៣–៦០

៦– កែវ ខេន ស្រី ១៧–៧–៧០

៧– ចិន សំអាន ប្រុស ២០–៦–៧០

៦– មន្ទីរប,ឧ ខេត្តកោះកុង :

១– ផុយ វណ្ណៈ ប្រុស ១៥–០១–៧៣

២– ជ័យ ឧត្តម – ០៧–៤–៧៥

៣– ឌី សុខុម ស្រី ៦០

៧– មន្ទីរប,ឧ ខេត្តស្វាយរៀង :

១– ចាន់ រ៉ូប៊ិនសុន ប្រុស ០៨–៤–៧៤

២– អន សារុន – ១៨–៣–៧៦

៨– មន្ទីរប,ឧ ខេត្តសៀមរាប :

១– សុង បុង ប្រុស ១១–០១–៧៤

៩– មន្ទីរប,ឧ ខេត្តព្រៃវែង :

១– ប្រាក់ សើរ ស្រី ០៥–០១–៧៣

២– លាង លី – ១៥–១២–៧១

១០– មន្ទីរប,ឧ ខេត្តកំពត :

១– ពៅ សីលា ប្រុស ១៨–១០–៧៧

១១– មន្ទីរប,ឧ ខេត្តកំពង់ធំ :

១– កុយ វ៉ាឌី ប្រុស ០១–៣–៧៧

២– ជឹម ជីប៉ារ៉ូ ស្រី ១៥–៥–៧៧

១២– មន្ទីរប,ឧ ខេត្តព្រះវិហារ :

១– នៅ ពៅ ស្រី ០២–៤–៧៨

២– ស៊ឹម សៀងលី ស្រី ០១–៨–៧៣

៣– ស សារ៉ាវុធ ប្រុស ១០–០២–៧៧

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧត្ថម្ភផ្សេងៗ របស់សាមីខ្លួន ក្រសួងមានភារកិច្ចរៀបចំទៅតាមសមត្ថភាព និង មុខជំនាញបច្ចេកទេស ។

ប្រការ ៣ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច , គ្រប់បណ្តាក្រសួង ខេត្ត ក្រុង និងសាមីខ្លួនទាំង ៥៨ រូប ត្រូវទទួលអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៣៨ បន.ប្រក.

-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីទីការតែងតាំងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ០៥-៣-៨៧ ស្តីពីប្រៃសណីយ៍ និង ទូរគមនាគន៍

-បានឃើញពាក្យស្នើសុំឈប់ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF របស់ក្រុមហ៊ុន POLYMAX INTERNATIONAL DEVELOPMENT INVE - STANT CO.LTD ចុះថ្ងៃទី ០៥-៣-៩៦

-ប្រកាសលេខ ១១១ បទ.ប្រកទអ. ចុះថ្ងៃទី ១៣-៩-៩៤

សម្រេច

ប្រការ ១ : អនុញ្ញាតអោយលោកជំទាវ **ញ៉ែម សេដ្ឋា** ផ្អាកការប្រើប្រាស់ទីតាំងវិទ្យុទាក់ទងប្រភេទ **VHF** ចំនួន ៣ គ្រឿង ។

ប្រការ ២ : ប្រកាសលេខ ១១១ បទ.ប្រកទអ. ចុះថ្ងៃទី ១៣-៩-៩៤ ទុកជានិរាករណ៍ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស

នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង លោកជំទាវ ញៀម សេដ្ឋា ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ យុន

* * *

៩— រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ១៦៦ សសរ.មស.ក្រខ
ស្តីពីការការបែងចែកសិស្សនិស្សិតចំនួន ១០ នាក់
ដែលទើបបញ្ចប់ការសិក្សា ក្រៅប្រទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចនរោត្តមព្រះ **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨.០២.១៩៩៥

២—ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទចំនួន ០១ នាក់

ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

៤	សែម បុទ្ធិវឌ្ឍី	ប	០១.០២.៧០	–	ផ្នែកកសិកម្ម	៩០ខ I១	២

៣—ក្រសួងសុខាភិបាលចំនួន ០២ នាក់

ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

៥	ហាយ ឡាអ៊ីន	ប	១៨.០៩.៧២	សិស្ស	វេជ្ជសាស្ត្រទូទៅ	៩០ខ I១	៣
៦	អ៊ុក ពិសិដ្ឋ	ស្រី	១៩.០៩.៦២	សិស្ស	ភេសជ្ជសាស្ត្រនិង សម្ផ	៩០ខ I១	១

៤—ក្រសួងសាធារណៈការ និង ដឹកជញ្ជូនចំនួន ០២ នាក់

ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

៧	ចាន់ ប៊ុណ្ណារ៉ាត	ប	២២.៧.៦៩	សិស្ស	សំណង់ស៊ីវិល	៩០ខ I១	១
៨	ចាយ ពន្លក	ប	០៧.៩.៧១	សិស្ស	សំណង់ស៊ីវិល	៩០ខ I១	១

៥—ក្រសួងពាណិជ្ជកម្មចំនួន ០១ នាក់

ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

៩	អ៊ុម ចាន់ថុល	ប	២៩.១១.៧០	សិស្ស	ទំនាក់ទំនងសេដ្ឋកិច្ច អន្តរជាតិ	៩០ខ I១	១

៦—ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន ០១ នាក់

ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

១០	សុក វុន	ប	០៤.៩.៧០	សិស្ស	ទំនាក់ទំនងសេដ្ឋកិច្ច អន្តរជាតិ	៩០ខ I១	១

បានបញ្ឈប់បញ្ជីត្រឹមចំនួន ១០ នាក់

« ដប់នាក់ » នាក់ប៉ុណ្ណោះ

ភ្នំពេញ , ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៨៦

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឡាត់ សុខ

កំណត់សំគាល់

១– សហព័ន្ធ រុស្ស៊ី

២– ប្រទេស អាល្លឺម៉ង់

៣– ប្រទេស វៀតណាម

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រកីតៃ ១ គរុកោសល្យចំនួន ០១ នាក់ អ្នក បច្ចេកទេសថ្នាក់ឧត្តម ចំនួន ០៩ នាក់ ដែលបានបញ្ចប់ការសិក្សាពីក្រៅប្រទេសត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមក្រសួងស្ថាប័នមួយចំនួនដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃ សេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

តារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ១១៦ សសរ.មសព្រខ
ចុះថ្ងៃទី ០៤ ខែ ៣ ឆ្នាំ ១៩៨៦ ស្តីពីការបែងចែកសិស្ស
និស្សិតចំនួន ១០ នាក់ ដែលទើបបញ្ចប់ការសិក្សាពី ក្រៅប្រទេស

* * *

ល.រ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញបច្ចេកទេស	បៀវត្ស	ប្រភពបណ្ដុះបណ្ដាល
	១—ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិចំនួន ០៣ នាក់						
	ក– អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រកីតៃ ១ គរុកោសល្យចំនួន ០១ នាក់						
១	មាស ស៊ីបសីណា	ស្រី	១០.០១.៦៧	បុឈិ.ក្រសួងការបរទេស	ទស្សនវិជ្ជាផ្នែកភាសារុស្ស៊ី	ខ I៤	២
	ក– អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់						
២	ហាវ តេនះ	ប	១០.១១.៧៣	សិស្ស	ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ	៩០ខ I១	១
៣	ឌិក សារ៉ា	ប	០៩.៥.៧១	—	ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ	-	១

១០– ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៥៧/៩៦ ក.ធ.ស

«ស្តីពីការអនុញ្ញាតិច្បាប់ អោយមានស្នាក់ការថ្វាយបង្គំព្រះ ប្រកាសដំណឹងល្អ ពីព្រះយេស៊ូគ្រីស្ទ ខេត្តកណ្តាល

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–បានឃើញព្រះរាជក្រម ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយ ប្រើតាមលេខ នស.រកម ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

–បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

–បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ. ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

–បានឃើញពាក្យស្នើសុំច្បាប់ បើកស្នាក់ការថ្វាយបង្គំព្រះ និង ប្រកាសដំណឹងល្អពីព្រះយេស៊ូគ្រីស្ទ «និកាយប្រូតេស្តង់ » ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍ អោយមានស្នាក់ការថ្វាយបង្គំព្រះ និង ប្រកាស

ដំណឹងល្អពីព្រះយេស៊ូគ្រីស្ត « និកាយប្រូតេស្តង់ » មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិអូរអណ្តូង ឃុំចាគួរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះ និងប្រកាសដំណឹងល្អពីព្រះយេស៊ូគ្រីស្ត « និកាយប្រូតេស្តង់ » ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រីស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ស្នាក់ការថ្វាយបង្គំព្រះ និង ប្រកាសដំណឹងល្អព្រះយេស៊ូគ្រីស្ត « និកាយប្រូតេស្តង់ » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា សន្យាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារ័ត្ន

* * *

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៨៦

ប្រកាសលេខ ៦៨/៩៦ កធស. ប្រក

ស្តីពីការបង្កើតមន្ទីរធម្មការ និង សាសនាក្រុងកែប

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រម ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនាដែលប្រកាសអោយប្រើតាមលេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ២២ អ.ន.ក្រ. ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

- អនុលោមតាមការងារចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : បង្កើតមន្ទីរធម្មការ និងសាសនាក្រុងកែប ដែលមានការិយាល័យ ៣ ការិយាល័យរដ្ឋបាល ការិយាល័យធម្មការ និងសាសនា ការិយាល័យពុទ្ធិកសិក្សា និង ការិយាល័យធម្មការខ័ណ្ឌ ២ ខ័ណ្ឌដំណាក់ចង្អេរ ខ័ណ្ឌកែប សរុបមាន ១១ កន្លែង ។

ប្រការ ២ : មន្ទីរធម្មការ និង សាសនាមានប្រធានមន្ទីរម្នាក់ និង អនុប្រធានមន្ទីរម្នាក់ ជំនួយការ ។

ប្រការ ៣ : អភិបាលក្រុងកែប មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុក្រុងកែប និងមន្ទីរធម្មការ និង សាសនាក្រុងកែបសហការអនុវត្តតាមសេចក្តីប្រកាសនេះ ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១១១០ រៀល